ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ : ....៤៧៧....ប.ទ..... ថ្ងៃព្រហស្បតិ៍ ១០រោច ខែដប្បទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៩ ឆ្នាំ២០២៣

សេចក្តីជូនដំណឹង
ស្តីពី
ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាឱ្យចូលបម្រើការងារតាមបណ្តាអង្គភាពចំណុះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល (គ.រ.ឌ.)

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនដំណឹងដល់សាធារណជននិងនិស្សិត ជ្រាបថា ដើម្បីជួយគាំទ្រដល់ដំណើរការនិងធានានិរន្តរភាពការងារកសាងរដ្ឋាភិបាលឌីជីថល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាចំនួន ៣២នាក់ ឱ្យបម្រើការងារតាមបណ្តាអង្គភាពចំណុះអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ដូចខាងក្រោម៖

- បុគ្គលិករចនាផ្នែកខាងមុខនៃកម្មវិធីសម្រាប់អ្នកប្រើប្រាស់ (UI/UX Designer)	ចំនួន ៣នាក់
- បុគ្គលិកអភិវឌ្ឍសុសវែរទូរសព្ទដែលប្រើប្រាស់ Flutter	ចំនួន ៣នាក់
- បុគ្គលិកអភិវឌ្ឍផ្នែកខាងមុខប្រើប្រាស់ React និង Angula CLI	ចំនួន ៣នាក់
- បុគ្គលិកជំនាញធ្វើតេស្តធានាគុណភាពប្រព័ន្ធ (QA-Tester)	ចំនួន ២នាក់
- បុគ្គលិកអភិវឌ្ឍផ្នែកខាងក្រោយនិងអភិវឌ្ឍ API	ចំនួន ៣នាក់
- បុគ្គលិកវិស្វករ DevOp (DevOp Engineer)	ចំនួន ២នាក់
- បុគ្គលិកតេស្តសាកល្បងសុវត្ថិភាពនៃប្រព័ន្ធ (Penetration Tester)	ចំនួន ២នាក់
- បុគ្គលិកដាក់ឱ្យប្រើប្រាស់ និងគាំទ្របច្ចេកវិទ្យាព័ត៌មាន (System Delivery and Support)	ចំនួន ២នាក់
- បុគ្គលិកវិភាគទិន្នន័យ (Data Analyst)	ចំនួន ២នាក់
- បុគ្គលិកសម្របសម្រួលគម្រោងព័ត៌មានវិទ្យា (IT Project Coordinator)	ចំនួន ២នាក់
- បុគ្គលិកទំនាក់ទំនងសាធារណៈ សហប្រតិបត្តិការ និងផ្សព្វផ្សាយ	ចំនួន ២នាក់
- បុគ្គលិកគោលនយោបាយ	ចំនួន ១នាក់
- បុគ្គលិកនីតិកម្ម	ចំនួន ១នាក់
- បុគ្គលិកសម្របសម្រួលកម្មវិធី	ចំនួន ១នាក់
- បុគ្គលិកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ	ចំនួន ២នាក់
- បុគ្គលិករៀបចំផែនការ សរុប និងស្ថិតិ	ចំនួន១នាក់។

១. លក្ខខណ្ឌនៃការជ្រើសរើស

- បេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឡើងទៅ ស្របតាមជំនាញជ្រើសរើស
- មានចំណេះដឹងភាសាអង់គ្លេសអាចប្រើការបាន

- មានឆន្ទៈ និងក្រមសីលធម៌បំពេញការងារ
- មានភាពស្មោះត្រង់ និងយកចិត្តទុកដាក់ចំពោះការងារ
- មានភាពអត់ធ្មត់ តស៊ូ និងឧស្សាហ៍ព្យាយាម
- មានសមត្ថភាពបំពេញការងារដោយឯករាជ្យ និងការងារជាក្រុម
- មានគំនិតផ្តួចផ្តើម និងច្នៃប្រឌិត
- ទទួលយកការបណ្តុះបណ្តាលចំណេះដឹងបន្ថែម
- ទទួលភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីអ្នកគ្រប់គ្រង។

២. ភារកិច្ច ការទទួលខុសត្រូវ និងគុណវុឌ្ឍិ

- សូមមើលនៅក្នុងផ្នែកភារកិច្ច ការទទួលខុសត្រូវ និងគុណវុឌ្ឍិតាមជំនាញនីមួយៗ ដែលភ្ជាប់មកជាមួយសេចក្តីជូនដំណឹងនេះ។

៣. ប្រាក់បៀវត្ស និងអត្ថប្រយោជន៍

- ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែស្របតាមមុខតំណែង សមត្ថភាព បទពិសោធ និងគុណវុឌ្ឍិរបស់បេក្ខជន
- ទទួលបានចំណេះដឹង និងជំនាញឯកទេសវិជ្ជាជីវៈបន្ថែមតាមរយៈការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស ការអនុវត្តការងារជាក្រុម និងការបង្ហាញភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ
- ឱកាសក្លាយជាមន្ត្រីរាជការដោយផ្អែកលើសមត្ថភាពនិងសមិទ្ធកម្មការងារ។

៤. កាលបរិច្ឆេទទទួលពាក្យ និងនីតិវិធីនៃការជ្រើសរើស

- បេក្ខជន ឬបេក្ខនារី ដែលមានចំណាប់អារម្មណ៍ត្រូវបំពេញពាក្យស្នើសុំតាម QR Code ដែលភ្ជាប់មកខាងក្រោម ព្រមទាំងភ្ជាប់សំណុំឯកសារពាក់ព័ន្ធផ្សេងៗចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់**ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣** វេលាម៉ោង ១៧:០០នាទី។
- បេក្ខជនដែលបានជាប់ដំណាក់កាលសម្រាំងជ្រើសរើស (Shortlist) នឹងត្រូវទាក់ទងឱ្យមកធ្វើបទបង្ហាញ ឬមកសម្ភាសជាមួយគណៈកម្មការជ្រើសរើស។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈលេខទូរសព្ទ ០៩២ ៨៨៦ ២៤២ ឬអ៊ីមែល hr@dgc.gov.kh។

ស្កេន QR Code ដើម្បីបំពេញពាក្យស្នើសុំ



បុគ្គលិករចនាផ្នែកខាងមុខនៃកម្មវិធីសម្រាប់អ្នកប្រើប្រាស់
(User Interface/User Experience (UI/UX) Designer)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- ប្រមូល និងវាយតម្លៃតម្រូវការរបស់អ្នកប្រើប្រាស់ដើម្បីរៀបចំឬអភិវឌ្ឍគេហទំព័រ ឬផតថល
- អភិវឌ្ឍ និងបង្កើតយុទ្ធសាស្ត្រចនា UI/UX ទូលំទូលាយ
- ប្រមូលផ្តុំ និងវាយតម្លៃតម្រូវការអ្នកប្រើប្រាស់
- បង្ហាញគំនិតរចនាដោយប្រើ Storyboards ដំណើរការ និងផែនទីគេហទំព័រ
- រចនាធាតុក្រាហ្វិកផ្តាំងអ្នកប្រើប្រាស់ ដូចជា menus, tabs និង widgets
- ដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងបញ្ហា UX ទាក់ទងនឹងការឆ្លើយតបទាន់ពេលវេលា (Responsiveness)
- បង្កើតគំរូ UI និងគំរូដើម (Prototypes) ដែលបង្ហាញយ៉ាងច្បាស់អំពីរូបរាងនិងរបៀបដំណើរការគេហទំព័រ
- រៀបចំ និងបង្ហាញសេចក្តីព្រាង ឬគម្រូជូនក្រុមការងារនិងអ្នកពាក់ព័ន្ធសំខាន់ៗ
- ប្រកាន់ខ្ជាប់នូវស្តង់ដារចនាលើពុម្ពអក្សរ ពណ៌ និងរូបភាព
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- កម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្រឬសញ្ញាបត្រសមមូលឡើងទៅ ផ្នែកព័ត៌មានវិទ្យា ឬជំនាញពាក់ព័ន្ធ
- មានបទពិសោធការងារ ផ្នែកវិភាគប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន វិភាគលំហូរដំណើរការនៃប្រតិបត្តិការអាជីវកម្ម ឬ IT Product Owner
- មានបទពិសោធធ្វើជាអ្នកគ្រប់គ្រងប្រព័ន្ធ កម្មវិធី ឬវិស្វករបច្ចេកទេស (Technical Engineer)
- មានបទពិសោធការងារយ៉ាងតិច ៣ទៅ៥ឆ្នាំ ជាអ្នករចនា UI/UX ឬតួនាទីប្រហាក់ប្រហែល
- មានមូលដ្ឋានគ្រឹះរឹងមាំក្នុងការប្រើប្រាស់កម្មវិធីរចនារួមមាន Adobe XD, Sketch, Figma, Adobe InDesign Adobe illustrator និង Adobe Photoshop
- មានចំណេះដឹងអំពីការប្រើប្រាស់ឧបករណ៍ Wireframe ដូចជា Balsamiq និង In Vision
- មានចំណេះដឹងនិងគំនិតច្នៃប្រឌិតថ្មីៗ ពាក់ព័ន្ធនឹង Design Sprint, Lean UX និង Design Thinking
- មានសមត្ថភាពរៀបចំផែនការអភិវឌ្ឍ និងធ្វើឱ្យប្រសើរឡើងនូវរូបរាងផតថល ឬគេហទំព័រ
- មានភាពបត់បែន សកម្ម អាចបង្កើតគំនិត និងបង្កើតដំណោះស្រាយចំពោះបញ្ហា
- មានកិច្ចសហការល្អជាមួយក្រុមការងារក្នុងការអនុវត្តកម្មវិធី/គម្រោងដែលមានលក្ខណៈស្មុគស្មាញ។

****

បុគ្គលិកអភិវឌ្ឍសុសវែរទូរសព្ទដែលប្រើប្រាស់ Flutter
(Mobile App Development Using Flutter)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- រចនា និងបង្កើតកម្មវិធីទូរសព្ទដែលទំនើប និងអាចប្តូរមាត្រដ្ឋានបាន ដោយប្រើ Flutter
- បង្កើតកញ្ចប់ដែលអាចធ្វើការផ្លាស់ប្តូរបាននៅក្នុង Flutter ដោយប្រើប្រាស់មុខងារផ្សេងៗ និង APIs ដែលមានស្រាប់នៅក្នុង Android និង iOS
- បកប្រែ និងបង្កើតការរចនា និង Wireframes ឱ្យទៅជាកូដ UI ដែលមានការឆ្លើយតបខ្ពស់
- ស្វែងរកនិម្មាបនកម្មដែលអាចធ្វើទៅបានសម្រាប់ការអនុវត្តមុខងារថ្មីៗ
- ដោះស្រាយបញ្ហាណាមួយដែលមាននៅក្នុងប្រព័ន្ធ ហើយស្នើ និងបន្ថែមមុខងារថ្មីៗនៅក្នុងប្រព័ន្ធ
- អនុវត្តតាមការណែនាំដែលល្អបំផុត នៅពេលដែលកំពុងបង្កើតកម្មវិធី ហើយក៏ត្រូវរក្សាអ្វីៗគ្រប់យ៉ាងឱ្យមានរបៀប និងទុកដាក់ជាឯកសារឱ្យបានល្អផងដែរ
- ប្រើ CI/CD សម្រាប់ការដាក់ឱ្យដំណើរការដោយរលូន
- ចងក្រងឯកសារគម្រោង និងកូដប្រកបដោយប្រសិទ្ធភាព
- អនុវត្តការកំណត់ពេលវេលា និងការវាយតម្លៃការបែកធ្លាយអង្គចងចាំ
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- មានបរិញ្ញាបត្រដែលទាក់ទងនឹងផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ឬសញ្ញាបត្រដែលពាក់ព័ន្ធ
- មានបទពិសោធការងារយ៉ាងតិច ៣ទៅ៥ឆ្នាំ ក្នុងការអភិវឌ្ឍគេហទំព័រ បង្កើតកម្មវិធីដែលផ្តោតលើទិន្នន័យ ដោយប្រើ Modern JavaScript Frameworks
- ជំនាញផ្នែក Flutter សម្រាប់ប្រព័ន្ធប្រតិបត្តិការ Android និង iOS
- មូលដ្ឋានគ្រឹះរឹងមាំនៅក្នុងគោលការណ៍នៃការបង្ហាញព័ត៌មាន
- ចំណេះដឹងរឹងមាំក្នុងនិម្មាបនកម្ម និងការអនុវត្តកម្មវិធី Android ឬ iOS
- មានសមត្ថភាពក្នុងការវិភាគ និងមានគំនិតច្នៃប្រឌិត។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលិកអភិវឌ្ឍផ្នែកខាងមុខដោយប្រើប្រាស់ React និង Angular CLI
(Front-end using React and Angular CLI)

ក. តារាងកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- ថែរក្សាប្រព័ន្ធ React ដែលមានស្រាប់ រួមទាំងការជួសជុលកំហុសផ្សេងៗ
- រចនា និងអភិវឌ្ឍសមាសធាតុថ្មីដោយផ្ទាល់ ដើម្បីបំពេញតម្រូវការគម្រោង
- ដំឡើងនិងកំណត់រចនាសម្ព័ន្ធបរិស្ថានម៉ាស៊ីន សម្រាប់ការដាក់ឱ្យប្រើ React
- ថែរក្សា និងធ្វើបច្ចុប្បន្នភាព Dependencies របស់គម្រោង ព្រមទាំងជួសជុលការប៉ះទង្គិចណាមួយ
- ធ្វើការជាមួយអ្នកអភិវឌ្ឍ JavaScript និងវិស្វកររុសរែរផ្សេងទៀត ដើម្បីបង្កើតនិម្មាបនកម្មផ្នែកខាងមុខ (Front-end) និងផ្នែកខាងក្រោយ(Back-end) ដែលមានរចនាសម្ព័ន្ធល្អ និងអាចបត់បែនបាន រួមជាមួយនឹង APIs ដើម្បីធ្វើការគាំទ្រ
- ការកែសម្រួលផ្នែខាងមុខសម្រាប់កម្មវិធីអ៊ីនធឺណិតទំនើប ដោយប្រើបច្ចេកវិទ្យាផ្នែខាងមុខចុងក្រោយបំផុត
- ការរចនាផ្ទាំងអ្នកប្រើប្រាស់ (User Interface) យោងទៅតាមការអនុវត្តល្អបំផុតរបស់ Angular
- បង្កើតកូដ និងតេស្តសម្រាប់កម្មវិធីក្នុង Angular
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ការអភិវឌ្ឍសុសរែរវិស្វកម្ម ឬផ្នែកបច្ចេកទេសពាក់ព័ន្ធ
- មានបទពិសោធពាក់ព័ន្ធ យ៉ាងតិច៣ទៅ៥ឆ្នាំឡើងទៅ
- ស្ទាត់ជំនាញជាមួយនឹងការអភិវឌ្ឍចុងក្រោយបំផុតនៃ ECMAScript (JavaScript) ក៏ដូចជា HTML និង CSS
- មានចំណេះដឹងអំពី React និងឧបករណ៍ទូទៅដែលប្រើនៅក្នុងប្រព័ន្ធអេកូ React ដូចជា Node.js និង npm
- មានចំណេះដឹងអំពី Angular, Next.js និងTailwind
- ស្គាល់ឧបករណ៍សរសេរកម្មវិធីទូទៅដូចជា Redux, IDEs, RESTful APIs, Git Repositories, TypeScript, Version Control Software និង Remote Deployment Tools
- ការយល់ដឹងអំពីគំរូនៃការសរសេរកម្មវិធីទូទៅ និងគោលការណ៍ React ជាមូលដ្ឋាន ដូចជា React components, hook និងវដ្តជីវិតរបស់ React។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលិកជំនាញធ្វើតេស្តធានាគុណភាពប្រព័ន្ធ
(QA-Tester)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- ធ្វើតេស្តមុខងារ
- ធ្វើតេស្ត Load
- ធ្វើតេស្ត API
- ធ្វើការដំណើរការ និងសាកល្បងកម្មវិធី និងសុសវែរថ្មីៗ
- អនុវត្តរាល់កម្រិតនៃការធ្វើតេស្ត QA ដែលជា System, Integration និងRegression
- បង្កើតការរចនាសាកល្បង ដំណើរការសាកល្បង ទិន្នន័យសាកល្បង ការសាកល្បងស្វ័យប្រវត្តិកម្ម និងករណីសាកល្បង ហើយផ្តល់អាទិភាពដល់សកម្មភាពសាកល្បង
- កំណត់អត្តសញ្ញាណនៃកំហុស និងបង្កើតរបាយការណ៍ ដើម្បីរំលេចនូវស្ថានភាពនៃម៉ូឌុលទាំងអស់
- ធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ ដែលមានកំហុសទាំងអស់ ជាមួយនឹងព័ត៌មានដែលត្រឹមត្រូវ និងពេញលេញ
- ធ្វើការសម្របសម្រួលជាមួយក្រុមអភិវឌ្ឍនៃ Software QA Engineers និង Software Test Manager ដើម្បីបង្កើតផែនការ និងយុទ្ធសាស្ត្រសាកល្បងប្រកបដោយប្រសិទ្ធភាព
- ធ្វើការកែលម្អប្រព័ន្ធទៅតាមដំណាក់កាលនៃការអភិវឌ្ឍកម្មវិធី
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ បច្ចេកវិទ្យាព័ត៌មាន ឬសញ្ញាបត្រប្រហាក់ប្រហែល
- មានបទពិសោធពាក់ព័ន្ធនឹង QA Engineer, Software Tester ឬតួនាទីប្រហាក់ប្រហែល យ៉ាងតិច៣ ទៅ៥ឆ្នាំឡើងទៅ
- វិញ្ញាបនបត្រវិជ្ជាជីវៈដូចជា ISTQB និង CTFL Certifications
- ការយល់ដឹងប្រសើរលើវិធីសាស្ត្រអភិវឌ្ឍកម្មវិធីដូចជា Agile, Defect Management System និងការធានាគុណភាព និងឯកសារ
- មានចំណេះដឹងល្អលើ Selenium IDE, Selenium Web Driver, NUnit, Loadrunner, JMeter ជាដើម
- មានចំណេះដឹងផ្នើមក្នុងការរចនា និងសរសេរ Script តេស្តស្វ័យប្រវត្តិកម្ម
- មានជំនាញវិភាគ និងដោះស្រាយបញ្ហា
- ការយល់ដឹងពិសេសនៃការធ្វើតេស្តមូលដ្ឋានទិន្នន័យ SQL
- មានចំណេះដឹងលើការងារនៃភាសាសរសេរកម្មវិធីជាច្រើន។

****

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ 120210
123 023 724 810
www.mptc.gov.kh

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលិកអភិវឌ្ឍផ្នែកខាងក្រោយនិងអភិវឌ្ឍ API
(Back-end and API Developer)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- រចនា បង្កើត និងរក្សាកូដ ឱ្យមានប្រសិទ្ធភាព ប្រើឡើងវិញបាន និងអាចទុកចិត្តបាន
- ធានាឱ្យបាននូវប្រសិទ្ធភាព គុណភាព និងការឆ្លើយតបនៃកម្មវិធីដែលល្អបំផុត
- កំណត់បញ្ហារាំងស្ទះ និងបញ្ហាផ្សេងៗ ហើយបង្កើតដំណោះស្រាយចំពោះបញ្ហាទាំងនោះ
- ជួយរក្សាគុណភាពកូដ អង្គភាព និងស្ងួយប្រវត្តិកម្ម
- ចូលរួមក្នុងវដ្តជីវិតនៃការសរសេរកម្មវិធីទាំងមូល
- សហការជាមួយអ្នកអភិវឌ្ឍ Front-end
- បង្កើតកូដដែលអាចប្រើឡើងវិញបាន ដែលអាចប្រើបាននាពេលអនាគត
- សហការជាមួយក្រុមពហុជំនាញនៃអ្នករចនា អ្នកអភិវឌ្ឍ និងអ្នកគ្រប់គ្រងប្រព័ន្ធ
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានបរិញ្ញាបត្រផ្នែកកម្មវិធីកុំព្យូទ័រ វិទ្យាសាស្ត្រកុំព្យូទ័រ ឬបច្ចេកវិទ្យាព័ត៌មានវិទ្យា
- មានចំណេះដឹងលើ ASP.NET, Node.js, Python, Java, RESTful API, Database Management, Cloud Computing
- មានបទពិសោធជាអ្នកសរសេរកម្មវិធី អ្នកអភិវឌ្ឍយ៉ាងតិច៣ ទៅ៥ឆ្នាំ ឡើងទៅ
- សមត្ថភាពក្នុងការសរសេរកូដឱ្យបានស្អាត និងងាយយល់
- សមត្ថភាពវិភាគ និងពូកែដោះស្រាយបញ្ហា
- ការយល់ដឹងច្បាស់អំពីការសរសេរកូដ និងដំណើរការអភិវឌ្ឍ
- បទពិសោធការងារក្នុង Agile Environment។

****

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលិកវិស្វករ DevOp
(DevOp Engineer)

ក. តារាកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- អនុវត្តការអភិវឌ្ឍ ការធ្វើតេស្ត ឧបករណ៍ស្វ័យប្រវត្តិកម្ម និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាផ្សេងៗ
- កំណត់ និងដាក់ការអភិវឌ្ឍសាកល្បង ចេញផ្សាយ ធ្វើបច្ចុប្បន្នភាព និងដំណើរការគាំទ្រសម្រាប់ប្រតិបត្តិការ DevOps
- មានជំនាញបច្ចេកទេសក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងសុពលភាពកូដសុសវែរដែលបានបង្កើតនៅក្នុងគម្រោង
- ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ CI/CD ដែលសមស្រប
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានបរិញ្ញាបត្រផ្នែកកម្មវិធីកុំព្យូទ័រ វិទ្យាសាស្ត្រកុំព្យូទ័រ ឬបច្ចេកវិទ្យាព័ត៌មានវិទ្យា
- មានចំណេះដឹងលើ Linux, Docker, Kubernetes, Jenkins, CI/CD, scripting, infrastructure as code
- មានបទពិសោធជាអ្នកសរសេរកម្មវិធី អ្នកអភិវឌ្ឍយ៉ាងតិច៣ទៅ៥ឆ្នាំឡើងទៅ
- សមត្ថភាពក្នុងការសរសេរកូដឱ្យបានស្អាត និងងាយយល់
- សមត្ថភាពវិភាគនិងដោះស្រាយបញ្ហា
- ការយល់ដឹងច្បាស់អំពីការសរសេរកូដ និងដំណើរការអភិវឌ្ឍ។

****



បុគ្គលិកតេស្តសាកល្បងសុវត្ថិភាពនៃប្រព័ន្ធ
(Penetration Tester)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- ធ្វើតេស្តលើកម្មវិធី ឧបករណ៍បណ្តាញ និងហេដ្ឋារចនាសម្ព័ន្ធ cloud
- រចនា និងធ្វើការក្លែងធ្វើការវាយប្រហារតាមបែប Social Engineering
- ស្រាវជ្រាវ និងធ្វើការពិសោធការវាយប្រហារប្រភេទផ្សេងៗ
- បង្កើតវិធីសាស្ត្រសម្រាប់ការធ្វើតេស្តសាកល្បងសុវត្ថិភាពនៃប្រព័ន្ធ (Penetration testing)
- ពិនិត្យកូដសម្រាប់ភាពងាយរងគ្រោះផ្នែកសុវត្ថិភាព
- ប្តូរទិសដៅនៃ Engineer Malware or Spam
- ធ្វើបច្ចេកទេសសាកល្បងស្វ័យប្រវត្តិកម្មទូទៅ ដើម្បីបង្កើនប្រសិទ្ធភាព
- សរសេររបាយការណ៍បែបបច្ចេកទេស និងការប្រតិបត្តិការ
- ធ្វើឱ្យមានសុពលភាពនៃការកែលម្អសុវត្ថិភាព ជាមួយនឹងការធ្វើតេស្តបន្ថែម
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានបរិញ្ញាបត្រផ្នែកកម្មវិធីកុំព្យូទ័រ វិទ្យាសាស្ត្រកុំព្យូទ័រ ឬបច្ចេកវិទ្យាព័ត៌មានវិទ្យា
- មានចំណេះដឹងសម្រាប់ការធ្វើតេស្តសាកល្បងសុវត្ថិភាពនៃប្រព័ន្ធ (Penetration testing), Security protocols, Ethical hacking
- មានបទពិសោធក្នុងការធ្វើតេស្តប្រព័ន្ធ
- សមត្ថភាពវិភាគ និងពូកែដោះស្រាយបញ្ហា។

****



បុគ្គលិកជាក់ឱ្យប្រើប្រាស់ និងគាំទ្រប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
(System Delivery and Support)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- រៀបចំឯកសារណែនាំអ្នកប្រើប្រាស់ (User Manual)
- ត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាព ឯកសារណែនាំអ្នកប្រើប្រាស់ ក្នុងលក្ខខណ្ឌដែលមានការផ្លាស់ប្តូរ
- ធ្វើការជាមួយក្រុមការងារដែលពាក់ព័ន្ធ ដើម្បីរៀបចំផែនការដាក់ចេញនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួមមាន៖
    ១. បញ្ជីពិនិត្យនិងកាលវិភាគសម្រាប់ការដាក់ចេញនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
    ២. រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់បង្កើតការយល់ដឹងរបស់អ្នកប្រើប្រាស់
    ៣. បង្កើតនិងរៀបចំឯកសារបណ្តុះបណ្តាលនិងកាលវិភាគ
- ផ្តល់ការបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់នៅមូលដ្ឋានដោយផ្ទាល់ ឬការបញ្ជាពីចម្ងាយ
- ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយផ្អែកលើសូចនាករសំខាន់ៗដែលបានអនុម័ត
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ.គុណវុឌ្ឍិ

- បេក្ខជនត្រូវមានបរិញ្ញាបត្រផ្នែកកម្មវិធីកុំព្យូទ័រ វិទ្យាសាស្ត្រកុំព្យូទ័រ ឬបច្ចេកវិទ្យាព័ត៌មានវិទ្យាឬសញ្ញាបត្រសមមូលឡើងទៅ
- មានបទពិសោធការងារ ផ្នែកដាក់ចេញ និងគាំទ្រប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (System Delivery And Support)
- មានបទពិសោធក្នុងការធ្វើផែនការគាំទ្រប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- មានចំណេះដឹង ITIL, customer service, ticking systems, problem-solving, technical troubleshooting។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលិកវិភាគទិន្នន័យ
(Data Analyst)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- កំណត់ទិន្នន័យដែលត្រូវការក្នុងការវិភាគសម្រាប់ឱ្យក្រុមអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដាក់ឱ្យមានក្នុងប្រព័ន្ធ
- ថែរក្សាប្រព័ន្ធទិន្នន័យ និងមូលដ្ឋានទិន្នន័យ រួមបញ្ចូលទាំងការរាយការណ៍ពីកំហុសក្នុងការសរសេរកូដ និងបញ្ហាដែលទាក់ទងនឹងទិន្នន័យផ្សេងទៀតទៅឱ្យក្រុមអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានធ្វើការជួសជុល
- ប្រើប្រាស់ទិន្នន័យដើម្បីវិភាគអាកប្បកិរិយារបស់អ្នកប្រើប្រាស់ និងការប្រើប្រាស់ក្នុងប្រព័ន្ធ ដើម្បីបង្កើនចំនួនអ្នកប្រើប្រាស់
- រុករកទិន្នន័យពីប្រភពដែលមាននិងរៀបចំទិន្នន័យឡើងវិញតាមទម្រង់ដែលអាចយល់បានដោយមនុស្ស ឬម៉ាស៊ីន
- ប្រើប្រាស់ឧបករណ៍ ប្រព័ន្ធ កម្មវិធីដើម្បីបកស្រាយសំណុំទិន្នន័យដោយផ្តោតទៅលើនិន្នាការនិងលំនាំដែលអាចមានតម្លៃសម្រាប់ការវិនិច្ឆ័យ វិភាគ និងព្យាករណ៍របស់ស្ថាប័ន
- សហការជាមួយក្រុមដែលពាក់ព័ន្ធដើម្បីកំណត់ឱកាសសម្រាប់ការកែលម្អប្រព័ន្ធនិងបង្កើតគោលនយោបាយសម្រាប់ការគ្រប់គ្រងទិន្នន័យ
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានកម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ ផ្នែកបច្ចេកវិទ្យាព័ត៌មាន ឬជំនាញពាក់ព័ន្ធ
- មានបទពិសោធទាក់ទងនឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន ឬជំនាញពាក់ព័ន្ធយ៉ាងតិច៣ទៅ៥ឆ្នាំឡើងទៅ
- មានបទពិសោធធ្វើការជាមួយ MySQL, PostgreSQL, MongoDB, SQL Server ឬ Hive
- មានបទពិសោធជាមួយភាសាកូដ (Programming Language) ដូចជា R, Python, data visualization, data mining និង machine learning
- មានចរិតលក្ខណៈ ផ្តួចផ្តើមគំនិត ធ្វើការជាក្រុម និងច្បាស់លាស់ជាមួយការងារ។

****

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ 120210
123 023 724 810
www.mptc.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលិកសម្របសម្រួលគម្រោងបច្ចេកវិទ្យាព័ត៌មាន
(IT Project Coordinator)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- តាមដានគម្រោងបច្ចេកវិទ្យាព័ត៌មានដោយផ្អែកលើកាលវិភាគនៃការអនុវត្តផែនការដែលបានអនុម័ត
- កំណត់បញ្ហានិងរាយការណ៍ពីការគ្រប់គ្រងហានិភ័យដល់សមាជិកក្រុមការងារ និងថ្នាក់ដឹកនាំ
- ធ្វើបច្ចុប្បន្នភាពនិងរាយការណ៍ពីស្ថានភាពគម្រោងទៅដល់អ្នកប្រើប្រាស់និងសមាជិកក្រុមការងារ
- កំណត់និងគ្រប់គ្រង Dependencies របស់គម្រោង ទៅលើវិសាលភាព គម្រោង ពេលវេលា និងធនធានមនុស្ស
- ធានាឱ្យបាននូវទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរវាង អ្នកប្រើប្រាស់ និងសមាជិក
- ធានាថាឯកសារដែលពាក់ព័ន្ធ និងគម្រោងត្រូវបានរក្សាទុកដោយសុវត្ថិភាពសំរាប់ការធ្វើសវនកម្ម
- សហការជាមួយក្រុមដែលពាក់ព័ន្ធ ក្នុងការវាស់វែង តាមដានលទ្ធផល និងប្រសិទ្ធភាពការងារបន្ទាប់ពីដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានិងរាយការណ៍ពីចំណុចត្រូវកែលម្អជូនដល់ថ្នាក់ដឹកនាំ
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានកម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ ផ្នែកបច្ចេកវិទ្យាព័ត៌មាន ឬជំនាញពាក់ព័ន្ធ
- មានចំណេះដឹងផ្នែកគ្រប់គ្រងគម្រោង វិធីសាស្ត្រទន់ភ្លន់ (Agile methodologies) សម្របសម្រួលក្រុមការងារ ទំនាក់ទំនង និងថវិកា
- មានបទពិសោធផ្នែកសម្របសម្រួលគម្រោងបច្ចេកវិទ្យាព័ត៌មានយ៉ាងតិច៣ទៅ៥ឆ្នាំឡើងទៅ
- អាចប្រើប្រាស់ទាំងការនិយាយនិងការសរសេរជាភាសាអង់គ្លេស និងខ្មែរបានល្អ
- មានភាពជាអ្នកដឹកនាំ និងគំនិតច្នៃប្រឌិតក្នុងការវិភាគដោះស្រាយបញ្ហា
- មានការយកចិត្តទុកដាក់ខ្ពស់និងពិនិត្យយ៉ាងល្អិតល្អន់ ទៅលើការងារកំពុងអនុវត្ត។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលិកទំនាក់ទំនងសាធារណៈ សហប្រតិបត្តិការ និងផ្សព្វផ្សាយ

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- ប្រមូលព័ត៌មានទាក់ទងនឹងការអនុវត្តគោលនយោបាយនានាពាក់ព័ន្ធនឹងបរិវត្តកម្មរដ្ឋាភិបាលឌីជីថល
- ទំនាក់ទំនង និងសម្របសម្រួលការងារផ្ទៃក្នុង ឬអង្គភាពពាក់ព័ន្ធ
- ពិនិត្យរៀបចំ សម្របសម្រួល និងសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំកិច្ចប្រជុំ សិក្ខាសាលា សន្និសីទ ព្រឹត្តិការណ៍ចែករំលែកចំណេះដឹង និងយន្តការផ្សព្វផ្សាយនានា
- សម្របសម្រួល និងអនុវត្តពិធីការទស្សនកិច្ចរបស់ភ្ញៀវ ដៃគូជាតិនិងអន្តរជាតិ និងថ្នាក់ដឹកនាំ
- រៀបចំលិខិតឆ្លើយតប និង ឯកសារពាក់ព័ន្ធជូនដៃគូជាតិនិងអន្តរជាតិ និងស្ថាប័នផ្សេងៗ
- តាមដានការអនុវត្តកិច្ចសហប្រតិបត្តិការជាមួយដៃគូ
- រៀបចំឯកសារសហប្រតិបត្តិការនានាជាមួយដៃគូ
- សម្របសម្រួលការងាររដ្ឋបាល ពិធីការ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ ជាមួយដៃគូជាតិនិងអន្តរជាតិ
- ចូលរួមអនុវត្តតាមគម្រោងផែនការនៃការងារប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រ
- តាមដាននិងវាយតម្លៃកម្រិតនៃការយល់ដឹង ការគាំទ្រ និងការចូលរួមក្នុងបេសកកម្មបរិវត្តកម្មរដ្ឋាភិបាលឌីជីថលរបស់រាជរដ្ឋាភិបាល
- កំណត់តម្រូវការផ្សព្វផ្សាយ ព្រមទាំងលើកសំណើនិងអនុវត្តសកម្មភាព គម្រោង និងកម្មវិធីផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹង ការគាំទ្រ និងការចូលរួមក្នុងបេសកកម្មបរិវត្តកម្មរដ្ឋាភិបាលឌីជីថលរបស់រាជរដ្ឋាភិបាល
- បង្កើតនិងចងក្រងមាតិកាដើម្បីពន្យល់អំពីគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត កម្មវិធី គម្រោង និងសកម្មភាពពាក់ព័ន្ធនឹងបរិវត្តកម្មរដ្ឋាភិបាលឌីជីថលរបស់រាជរដ្ឋាភិបាល
- ចូលរួមក្នុងកិច្ចការគោលនយោបាយនិងកិច្ចការនីតិកម្មរបស់នាយកដ្ឋាន
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- មានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅផ្នែកទំនាក់ទំនងអន្តរជាតិ ច្បាប់ គោលនយោបាយ អក្សរសាស្ត្រអង់គ្លេស ផ្សព្វផ្សាយ ពាណិជ្ជសាស្ត្រ រដ្ឋបាលសាធារណៈ ឬសញ្ញាបត្រជំនាញប្រហាក់ប្រហែល
- មានបទពិសោធលើការងាររដ្ឋបាល ពិធីការ ទំនាក់ទំនងសាធារណៈ ទំនាក់ទំនងអន្តរជាតិ ផ្សព្វផ្សាយ ឬបទពិសោធប្រហាក់ប្រហែល
- មានបទពិសោធរៀបចំផែនការបណ្តុះបណ្តាល និងចូលរួមដោយផ្ទាល់ក្នុងការចែករំលែកចំណេះដឹង
- មានបទពិសោធសរសេរអត្ថបទខ្លីៗ សេចក្តីប្រកាសព័ត៌មាន ឬអត្ថបទផ្លូវការនានា
- អាចប្រើភាសាខ្មែរនិងភាសាអង់គ្លេស ទាំងនិយាយនិងសរសេរបានល្អ
- មានឆន្ទៈខ្ពស់លើការងារទំនាក់ទំនងអន្តរជាតិ និងសាធារណៈ
- មានការយល់ដឹងអំពីសេដ្ឋកិច្ចនិងសង្គមឌីជីថល និងរដ្ឋាភិបាលឌីជីថល (ជាការប្រសើរ)។

****

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលិកគោលនយោបាយ

ក. តារាកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- ស្វែងរក ចងក្រង និងសិក្សាឯកសារគោលនយោបាយកម្ពុជា បរទេស និងអន្តរជាតិគ្រប់ប្រភេទ របាយការណ៍ស្រាវជ្រាវ អត្ថបទសិក្សា ព្រមទាំងឯកសារផ្សេងទៀត
- ស្វែងរក ប្រមូល ចងក្រង និងវិភាគទិន្នន័យ
- ស្រាវជ្រាវ វិភាគ និងលើកយោបល់ផ្នែកគោលនយោបាយ ពាក់ព័ន្ធនឹងការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល
- ចូលរួមក្នុងការរៀបចំ ការសម្របសម្រួលការរៀបចំ និងការផ្តល់យោបល់លើសេចក្តីព្រាងឯកសារគោលនយោបាយគ្រប់ប្រភេទ
- តាមដាន និងរាយការណ៍ជាប្រចាំអំពីការវិវឌ្ឍគ្រប់ទិដ្ឋភាពនៃអភិបាលកិច្ចសាធារណៈ ការផ្តល់សេវាសាធារណៈ ឧស្សាហកម្មបច្ចេកវិទ្យា និងការចាប់យកនិងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់មហាជន
- ចូលរួមក្នុងកិច្ចការគោលនយោបាយនិងកិច្ចការនីតិកម្មរបស់នាយកដ្ឋាន
- ផ្តួចផ្តើមគំនិតនិងផ្តល់យោបល់ទៅលើកិច្ចការគោលនយោបាយរបស់នាយកដ្ឋាន
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណសុឱ្យ

- មានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ លើមុខជំនាញផ្សព្វផ្សាយ សារគមនាគមន៍ពាណិជ្ជសាស្ត្រ រដ្ឋបាលសាធារណៈ ទំនាក់ទំនងអន្តរជាតិ ឬមុខជំនាញពាក់ព័ន្ធផ្សេងទៀត
- មានបទពិសោធផ្នែកផ្សព្វផ្សាយ សារគមនាគមន៍ ទំនាក់ទំនងសាធារណៈ ឬបទពិសោធប្រហាក់ប្រហែល
- អាចប្រើភាសាខ្មែរ និងភាសាអង់គ្លេស ទាំងនិយាយនិងសរសេរបានល្អ
- មានការយល់ដឹងអំពីសេដ្ឋកិច្ចនិងសង្គមឌីជីថល និងរដ្ឋាភិបាលឌីជីថល (ជាការប្រសើរ)។

****



បុគ្គលិកនីតិកម្ម

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- ស្វែងរក ចងក្រង និងសិក្សាលិខិតបទដ្ឋានគតិយុត្តកម្ពុជា បរទេស និងអន្តរជាតិ របាយការណ៍ស្រាវជ្រាវ អត្ថបទសិក្សា ព្រមទាំងឯកសារផ្សេងទៀត បម្រើឱ្យមុខងាររបស់នាយកដ្ឋាន
- ស្រាវជ្រាវ វិភាគ និងលើកយោបល់ផ្នែកច្បាប់ ពាក់ព័ន្ធនឹងការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល
- ចូលរួមក្នុងការរៀបចំ ការសម្របសម្រួលការរៀបចំ និងការផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត
- ស្វែងរក ចងក្រង និងសិក្សាបទដ្ឋានពាក់ព័ន្ធនឹងកិច្ចការរៀបចំសេចក្តីព្រាងច្បាប់
- តាមដាននិងរាយការណ៍ជាប្រចាំអំពីការវិវត្តផ្នែកច្បាប់នៃអភិបាលកិច្ចសាធារណៈ ការផ្តល់សេវាសាធារណៈ ឧស្សាហកម្មបច្ចេកវិទ្យា និងការចាប់យកនិងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់មហាជន
- ចូលរួមក្នុងកិច្ចការគោលនយោបាយនិងកិច្ចការនីតិកម្មរបស់នាយកដ្ឋាន
- ផ្តួចផ្តើមគំនិតនិងផ្តល់យោបល់ទៅលើកិច្ចការនីតិកម្មរបស់នាយកដ្ឋាន
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណសុឱ្យ

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ លើមុខជំនាញនីតិកម្ម រដ្ឋបាលសាធារណៈ គោលនយោបាយ សេដ្ឋកិច្ច ឬមុខជំនាញពាក់ព័ន្ធផ្សេងទៀត
- មានបទពិសោធក្នុងវិស័យច្បាប់ រដ្ឋបាលសាធារណៈ គោលនយោបាយសាធារណៈ ឬវិស័យប្រហាក់ប្រហែល
- អាចប្រើភាសាខ្មែរនិងភាសាអង់គ្លេស ទាំងនិយាយនិងសរសេរបានល្អ
- មានការយល់ដឹងអំពីសេដ្ឋកិច្ចនិងសង្គមឌីជីថល និងរដ្ឋាភិបាលឌីជីថល (ជាការប្រសើរ)។

****



បុគ្គលិកសម្របសម្រួលកម្មវិធី

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- សម្របសម្រួលការងារពាក់ព័ន្ធនឹងកម្មវិធី/ គម្រោងវិនិយោគ គម្រោងបច្ចេកវិទ្យាឌីជីថល គម្រោងនវានុវត្តន៍ និងគម្រោងអភិវឌ្ឍផ្សេងៗ
- រៀបចំគម្រោងថវិកា និងផែនការសកម្មភាពសម្រាប់កម្មវិធី/គម្រោងដែលខ្លួនទទួលបន្ទុករៀបចំកំណត់ហេតុកិច្ចប្រជុំ របាយការណ៍វឌ្ឍនភាព របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍នានាពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី/ គម្រោង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធី/ គម្រោង និងផ្តល់យោបល់ក្នុងការធ្វើបច្ចុប្បន្នកម្មកម្មវិធី/ គម្រោងតាមការចាំបាច់ដើម្បីឆ្លើយតបនឹងការអនុវត្តជាក់ស្តែង
- ទំនាក់ទំនងនិងសហការជាមួយអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ ឬអង្គភាពពាក់ព័ន្ធនានា បូកសរុបលទ្ធផលនៃការអនុវត្តកម្មវិធី/ គម្រោងដែលខ្លួនទទួលបន្ទុក
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- មានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ លើជំនាញគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរដ្ឋបាលសាធារណៈ គ្រប់គ្រងពាណិជ្ជកម្ម សេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬសញ្ញាបត្រជំនាញប្រហាក់ប្រហែល
- មានបទពិសោធការងារពាក់ព័ន្ធនឹងការងារសម្របសម្រួលកម្មវិធី/ គម្រោង
- មានភាពអត់ធ្មត់ខ្ពស់ក្នុងការសម្របសម្រួលកម្មវិធី/គម្រោងដែលមានលក្ខណៈសុគស្មាញ
- មានសមត្ថភាពគ្រប់គ្រងកម្មវិធី/គម្រោងប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
- មានបទពិសោធ និងចំណេះដឹងពាក់ព័ន្ធនឹងរដ្ឋាភិបាលឌីជីថល(ជាការប្រសើរ)។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលិកត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- រៀបចំនីតិវិធី និងផែនការសកម្មភាពត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តគោលនយោបាយពាក់ព័ន្ធការកសាងនិងអភិវឌ្ឍរដ្ឋាភិបាលឌីជីថល
- កំណត់សូចនាករគន្លឹះនិងទិន្នន័យមូលដ្ឋានសម្រាប់ត្រួតពិនិត្យតាមដាននិងវាយតម្លៃ គោលនយោបាយពាក់ព័ន្ធការកសាងនិងអភិវឌ្ឍរដ្ឋាភិបាលឌីជីថល រយៈពេលខ្លី មធ្យម និងវែង
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តគោលនយោបាយពាក់ព័ន្ធការកសាងនិងអភិវឌ្ឍរដ្ឋាភិបាលឌីជីថល
- លើកសំណើកែសម្រួលវិធានគោលនយោបាយ និងគតិយុត្តតាមការចាំបាច់ និងរាយការណ៍ជូនប្រធាននាយកដ្ឋានត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ពិនិត្យ សម្រេចនិងចាត់វិធានការបន្ត
- ចងក្រង និងវិភាគទិន្នន័យគោលនយោបាយ និងគតិយុត្តសម្រាប់ធ្វើរបាយការណ៍ និងការសម្រេចចិត្តផ្នែកគោលនយោបាយ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណសុឱ្យ

- មានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ
- មានបទពិសោធយ៉ាងតិច៣ឆ្នាំ លើផ្នែកត្រួតពិនិត្យ តាមដាន និងវាយតម្លៃគម្រោង
- មានចំណេះដឹងភាសាអង់គ្លេសល្អទាំងការសរសេរនិងនិយាយ
- មានការទទួលខុសត្រូវខ្ពស់និងគោរពវិន័យការងារ
- មានស្មារតីធ្វើការជាក្រុម
- មានសមត្ថភាពក្នុងការយល់ដឹងពីការប្រើប្រាស់ប្រព័ន្ធកម្មវិធីកុំព្យូទ័របានឆាប់រហ័ស
- មានសមត្ថភាពក្នុងការសរសេររបាយការណ៍និងរៀបចំផែនការសកម្មភាពសម្រាប់ស្ថាប័ន
- មានស្មារតីចង់បន្តអភិវឌ្ឍសមត្ថភាព ចំណេះដឹង និងជំនាញ។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលិករៀបចំធ្វើផែនការ សរុបនិងស្ថិតិ

ក. តារាងកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- រៀបចំធ្វើបច្ចុប្បន្នភាព សហការ និងសម្របសម្រួលផែនការកសាង និងអភិវឌ្ឍរដ្ឋាភិបាលឌីជីថលជាមួយការិយាល័យជំនាញផ្សេងទៀត
- បូកសរុបទិន្នន័យ ស្ថិតិ និងរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តគោលនយោបាយពាក់ព័ន្ធការកសាង និងអភិវឌ្ឍរដ្ឋាភិបាលឌីជីថលដោយសហការ និងសម្របសម្រួលជាមួយការិយាល័យជំនាញផ្សេងទៀត
- រៀបចំ និងបូកសរុបកំណត់បង្ហាញ ជំនួយស្មារតី លទ្ធផលនិងកំណត់ហេតុនៃកិច្ចប្រជុំ/សិក្ខាសាលា និងបូកសរុបរបាយការណ៍ដោយសហការនិងសម្របសម្រួលជាមួយនឹងការិយាល័យជំនាញផ្សេងទៀត
- ផ្សព្វផ្សាយរបាយការណ៍កិច្ចប្រជុំ
- សហការ សម្របសម្រួល និងបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងបញ្ហាប្រឈមប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណសុឱ្យ

- មានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ
- មានបទពិសោធយ៉ាងតិច៣ឆ្នាំ លើផ្នែករៀបចំផែនការ សរុបនិងស្ថិតិ
- មានចំណេះដឹងភាសាអង់គ្លេសល្អទាំងការសរសេរនិងនិយាយ
- មានការទទួលខុសត្រូវខ្ពស់និងគោរពវិន័យការងារ
- មានស្មារតីធ្វើការជាក្រុម
- មានសមត្ថភាពក្នុងការយល់ដឹងពីការប្រើប្រាស់ប្រព័ន្ធកម្មវិធីកុំព្យូទ័របានឆាប់រហ័ស
- មានសមត្ថភាពក្នុងការសរសេររបាយការណ៍និងរៀបចំផែនការសកម្មភាពសម្រាប់ស្ថាប័ន
- មានស្មារតីចង់បន្តអភិវឌ្ឍសមត្ថភាព ចំណេះដឹង និងជំនាញ។

****